# សហគមន៍ខ្មែរកម្ពុជាក្រោម

**THE KHMER KAMPUCHEA KROM COMMUNITY**
**LA COMMUNAUTĖ DU KHMER KAMPUCHEA KROM**


# សេចក្តីថ្លែងការណ៍

ឯកឧត្តម ថាច់ សេដ្ឋា ប្រធានសហគមន៍ខ្មែរកម្ពុជាក្រោម និងជាអតីតសមាជិកព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា កាលរស់នៅកម្ពុជាក្រោម ធ្លាប់បួសនៅក្នុងព្រះពុទ្ធសាសនា ជាសាស្រ្តាចារ្យបង្រៀនកុលបុត្រកុលធីតាខ្មែរ ធ្លាប់រងទទួលនូវការធ្វើទុក្ខបុកម្នេញពីអាណានិគមយួន ភៀសខ្លួនមករស់នៅកម្ពុជា បន្តការតស៊ូមតិប្រឆាំងនឹងការធ្វើទុក្ខបុកម្នេញដល់ប្រជាពលរដ្ឋខ្មែរកម្ពុជាក្រោមរាប់លានរូប ដែលកំពុងរស់នៅក្រោមការត្រួតត្រារបស់យួន។

សហគមន៍ខ្មែរកម្ពុជាក្រោម ប្រចាំទ្វីបអាមេរិកខាងជើង ខកចិត្តយ៉ាងខ្លាំង ដែលអាជ្ញាធររាជធានីភ្នំពេញ ចាប់លោក ថាច់ សេដ្ឋា ដាក់ពន្ធនាគារព្រៃស នៅយប់ថ្ងៃចន្ទ ១០រោច ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី១៦ ខែមករា គ.ស.២០២៣។

សហគមន៍ខ្មែរកម្ពុជាក្រោម ប្រចាំទ្វីបអាមេរិកខាងជើង សូមអំពាវនាវដល់រាជរដ្ឋាភិបាលកម្ពុជា និងសាលាដំបូងរាជធានីភ្នំពេញ ដោះលែងលោក ថាច់ សេដ្ឋា ឱ្យមានសេរីភាពឡើងវិញ ដោយឥតលក្ខខ័ណ្ឌ ដើម្បីលោកមានលទ្ធភាពធ្វើការតស៊ូមតិ ដើម្បីការពារសិទ្ធិមនុស្សខ្មែរក្រោម៕

ថ្ងៃអាទិត្យ ១កើត ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ទីក្រុងឡូវ៉េល សហរដ្ឋអាមេរិក, ត្រូវនឹងថ្ងៃទី២២ ខែមករា គ.ស.២០២៣

**សហគមន៍ខ្មែរកម្ពុជាក្រោម នៃ ទ្វីបអាមេរិកខាងជើង**

**The Khmer Kampuchea Krom Community of North America**

សម្រាប់ព័ត៍មានបន្ថែម សូមទាក់ទងមក

លេខទូរស័ព្ទ៖ ៩៧៨.៥៩៦.៥១២៦